# សៀវភៅណែនាំ

# ការប្រើប្រាស់

# **ប្រព័ន្ធគ្រប់គ្រងព័ត៌មានបណ្ណាល័យ**

*សម្រាប់អ្នកប្រើប្រាស់ទូទៅ*

កំណែ 1.0.0

*(ខែមករា ឆ្នាំ២០២១)*

# មាតិកា

១) ទំព័រដើម........................................................................................................2

២) ព័ត៌មានលម្អិតរបស់ឯកសារ ..............................................................................................4

៣) ស្វែងរកលម្អិត ..........................................................................................................6

៣) ទំព័រផ្សេងៗ ..........................................................................................................8

# មាតិការូប

រូបទី 1 ទំព័រដើម....................................................................................................2

រូបទី 2 ទំព័រព័ត៌មានលម្អិតរបស់ឯកសារ ..........................................................................4

រូបទី 3 ឧទាហរណ៍នៃការស្វែងរកលម្អិត ...........................................................................6

រូបទី 4 ផ្ទាំងលទ្ធផលនៃការស្វែងរកលម្អិត ........................................................................7

## ១) ទំព័រដើម

នៅពេលដែលលោកអ្នកបើកវិសាយបណ្ណាល័យគ.ជ.អ.ប តាមរយៈអាយដ្ឋានវិបសាយ៖

**http://library.ncdd.gov.kh**

នោះលោកអ្នកនឹងបានឃើញទំព័រដើមនៃវិបសាយដូចខាងក្រោម៖




*រូបទី 1 ទំព័រដើម*

នៅលើទំព័រដើមនេះមានព័ត៌មាន និងមុខងារជាច្រើនសម្រាប់លោកអ្នក៖

- នៅផ្នែកលើឈាងខាងស្តាំ លោកអ្នកអាចផ្លាស់ប្តូរភាសាររបស់វិបសាយទាំងមូលរវាង ភាសាខ្មែរ និង ភាសាអង់គ្លេស (English)

- លោកអ្នកអាចស្វែងរកឯកសារដោយរហ័ស(Quick Search) ដោយវាយពាក្យគន្លឹះ(Keyword) ចូលទៅក្នុងប្រអប់នៅខាងក្រោមពាកថា *ស្វែងរកឯកសារ* រួចចុចលើប៊ូតុងស្វែងរក 

- នៅខាងស្តាំប្រអប់ *ស្វែងរកឯកសារ* លោកអ្នកនឹងបានឃើញ *ពាក្យគន្លឹះសំខាន់ៗ*ពីក្នុងឯកសារទាំងឡាយរបស់បណ្ណាល័យយើង
- នៅខាងក្រោមប្រអប់ *ស្វែងរកឯកសារ* លោកអ្នកនឹងបានឃើញ *បញ្ជីឯកសារដែលទើបនឹងបញ្ចូលថ្មីៗ* ដែលលោកអ្នកអាចចុចលើចំណងជើង ឬចុចលើប៊ូតុង *មើលព័ត៌មានលម្អិត* ដែលស្ថិតនៅខាងក្រោមផ្នែកខាងស្តាំនៃឯកសារនិមួយៗ
- ប្រសិនបើលោកអ្នកចុចលើឈ្មោះអ្នកបោះពុម្ពផ្សាយ នោះលោកអ្នកនឹងបានឃើញផ្ទាំងមួយដែលបង្ហាញរាល់ឯកសារដែលបានចេញផ្សាយដោយអ្នកបោះពុម្ពផ្សាយនោះទាំងអស់

## ២) ព័ត៌មានលម្អិតរបស់ឯកសារ

នៅពេលដែលលោកអ្នកចុចមើលព័ត៌មានលម្អិតរបស់ឯកសារណាមួយវានឹងបង្ហាញផ្ទាំងដូចខាងក្រោម៖




*រូបទី 2 ទំព័រព័ត៌មានលម្អិតរបស់ឯកសារ*

នៅលើទំព័រដើមនេះមានព័ត៌មាន និងមុខងារសម្រាប់លោកអ្នកដូចជា៖

- អ្នកនិពន្ធ៖ ប្រសិនបើលោកអ្នកចុចលើឈ្មោះអ្នកនិពន្ធ នោះនឹងមានទំព័រថ្មីមួយបើកឡើងដែលបញ្ជីឯកសារទាំងអស់ដែលជាស្នាដៃរបស់អ្នកនិពន្ធរូបនេះ

- អ្នកបោះពុម្ពផ្សាយ៖ ប្រសិនបើលោកអ្នកចុចលើឈ្មោះអ្នកបោះពុម្ពផ្សាយ នោះនឹងមានទំព័រថ្មីមួយបើកឡើងដែលបញ្ជីឯកសារទាំងអស់ដែលជាបានបោះពុម្ពផ្សាយដោយដោយអ្នកបោះពុម្ពផ្សាយនេះ
- ប្រធានបទ៖ ប្រសិនបើលោកអ្នកចុចលើប្រធានបទណាមួយ នោះនឹងមានទំព័រថ្មីមួយបើកឡើងដោយមានឯកសារទាំងអស់ដែលបានចាត់ចូលក្នុងប្រធានបទនេះ
- ពាក្យគន្លឹះ / ស្លាក៖ ប្រសិនបើលោកអ្នកចុចលើពាក្យគន្លឹះ / ស្លាកណាមួយ នោះនឹងមានទំព័រថ្មីមួយបើកឡើងដោយមានឯកសារទាំងអស់ដែលបានចាត់ចូលក្នុងពាក្យគន្លឹះ / ស្លាកនេះ
- តំណរខាងក្រៅ៖ ប្រសិនបើឯកសារនេះមានតំណរខាងក្រៅ (external link) នោះវានឹងបង្ហាញនៅទីនេះ
- នៅខាងក្រោមតំណរខាងក្រៅគឺជាបញ្ជីហ្វាល(file) ដែលលោកអ្នកអាចទាញយក(download) សម្រាប់ឯកសារមួយនេះ
- លោកអ្នកអាចបិទទំព័រនេះបានដោយចុចលើសញ្ញាខ្វែងនៅផ្នែកខាងលើឈាងខាងស្តាំ ឬចុចលើប៊ូតុង *បិទ* នៅផ្នែកខាងក្រោមឈាងខាងស្តាំ

## ៣) ស្វែងរកលម្អិត

លោកអ្នកអាចស្វែងរកលម្អិតបានតាមរយៈវាល(field)ខាងក្រោមណាមួយឬទាំងអស់ព្រមគ្នាក៏បាន៖

- ចំណងជើង
- អ្នកនិពន្ធ
- ប្រធានបទ
- ស្លាក/ពាក្យគន្លឹះ
- ឆ្នាំបោះពុម្ពផ្សាយ

ឧទាហរណ៍៖ ប្រសិនបើលោកអ្នកចង់ស្វែងរកកាតាឡុកដែលមានពាក្យថា *"ក្រុង ស្រុក"* នៅក្នុងចំណងជើង ហើយ បានចេញផ្សាយនៅឆ្នាំ*2014* នោះលោកអ្នកអាចធ្វើការស្វែងរកដូចតទៅ៖

1. វាយពាក្យថា *"ក្រុង ស្រុក"* (ដោយគ្មានធ្មេញកណ្ដុរ) ចូលទៅក្នុងប្រអប់ទី១ ហើយបញ្ជាក់ថា *ចំណងជើង* ត្រូវបានជ្រើយកក្នុង ប្រអប់ទី២
2. ចុចលើរូប*សញ្ញាលេខបូក* ដើម្បីឲ្យប្រអប់ថ្មីមួយទៀតបង្ហាញឡើង
3. សូមរក្សាពាក្យថា ***និង*** ឲ្យនៅដដែលក្នុងប្រអប់ទី១
4. វាយលេខ *2014* ជាលេខរូម៉ាំងចូលទៅក្នុងប្រអប់ទី២ ហើយជ្រើសយក *ឆ្នាំបោះពុម្ពផ្សាយ* ក្នុងប្រអប់ទី៣
5. ចុចលើប៊ូតុង *ស្វែងរក* ស្វែងរក




*រូបទី 3 ឧទាហរណ៍នៃការស្វែងរកលម្អិត*

នោះប្រព័ន្ធនឹងបង្ហាញនូវផ្ទាំងលទ្ធផលនៃការស្វែងរកដូចរូបខាងក្រោម ដែលលោកអ្នកអាច មើលព័ត៌មានលម្អិតដោយចុចលើចំណងជើងនៃឯកសារ ឬចុចលើប៊ូតុង មើលព័តមានលម្អិតនៅផ្នែកខាងក្រោមនៃឯកសារនិមួយៗក៏បាន។

**សំគាល់៖** ប្រសិនបើលោកអ្នកធ្វើការស្វែងរកឯកសារដោយប្រើប្រាស់វាល(field) ចាប់ពី២ឡើងទៅ នោះលោកអ្នកនឹងឃើញឈ្នាប់តក្ក(Logical conjunction) ***និង*** ហើយនឹង ***ឬ*** ។ ឈ្នាប់ ***និង*** អាចក្លាយជាការពិត

បានលុះត្រាតែគ្រប់លក្ខខណ្ឌទាំងអស់ត្រូវបានបំពេញ។ ផ្ទុយទៅវិញ ឈ្នាប់*ឬ* អាចក្លាយជាពិតបាន ឲ្យតែមានលក្ខខណ្ឌណាមួយត្រូវបានបំពេញគឺបានហើយ។




*រូបទី 4 ផ្ទាំងលទ្ធផលនៃការស្វែងរកលម្អិត*

## ៣) ទំព័រផ្សេងៗ

- អំពីបណ្ណាល័យ៖ រៀបរាប់អំពីបណ្ណាល័យគ.ជ.អ.ប
- ទំនាក់ទំនង៖ ទាក់ទងមកយើងខ្ញុំដើម្បីដោះស្រាយបញ្ហាបច្ចេកទេស ឬពេលលោកអ្នកមានជា សំណួរ មតិយោបល់ ឬសំណូមពរផ្សេងៗ
- ជំនួយ៖ លោកអ្នកអាចទាញយក*សៀវភៅណែនាំ សម្រាប់ អ្នកប្រើប្រាស់ទូទៅ* (សៀវភៅដែលលោកអ្នកកំពុងតែអាននេះ)

**សូមអរគុណ**